ក្រសួងសុខាភិបាល
លេខ...៣៧៣...ស.ខ.ល

# សារាចរណែនាំ
## ស្ដីពី
## វិធានការនៃការរួមចំណែកកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩

យោងតាមចំណារដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ប្រធានគណៈប្រចាំការ** នៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក) និងដើម្បីរួមចំណែកដល់ការកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដូចខាងក្រោម៖

១. ស្ថាប័នរដ្ឋ ក្រុមហ៊ុន សហគ្រាស រោងចក្រ និងទីតាំងដែលមានអង្គការចាត់តាំង ត្រូវធ្វើតេស្តជាប្រចាំទៅលើមន្ត្រីនិងបុគ្គលិករបស់ខ្លួន ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បន្តចែកចាយឧបករណ៍តេស្តរហ័សក្នុងតម្លៃដើម។

២. តំបន់ដែលមានផ្ទុះជំងឺកូវីដ-១៩ ជាតំបន់បិទខ្ទប់ ត្រូវបានកំណត់ធ្វើការវាយតម្លៃលើប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធ និងធ្វើតេស្តរហ័ស ឬធ្វើតេស្ត PCR ស្របតាមបទដ្ឋានបច្ចេកទេសសុខាភិបាល។

៣. កន្លែងយកសំណាកសាធារណៈដោយមន្ត្រីសុខាភិបាលមូលដ្ឋាន ឬក្រុមអ្នកស្ម័គ្រចិត្ត សម្រាប់ប្រជាពលរដ្ឋមិនមានលទ្ធភាពទិញឧបករណ៍តេស្តរហ័ស ត្រូវរៀបចំនៅតាមស្រុក ខណ្ឌ ឬឃុំ សង្កាត់។

៤. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បន្តលក់ឧបករណ៍តេស្តរហ័ស ២ខែទៀត ដើម្បីធ្វើឱ្យមានភាពសម្បូរនិងបន្សាំទៅនឹងតម្លៃទីផ្សារ។ បន្ទាប់មក ក្រសួងនឹងផ្ទេរការងារនេះឱ្យទៅអង្គភាពណាមួយទទួលខុសត្រូវបន្ត ឬទុកលទ្ធភាពឱ្យក្រុមហ៊ុនធ្វើអាជីវកម្មក្នុងតម្លៃសមស្រប។

៥. មន្ទីរពេទ្យឯកជននិងគ្លីនិកទាំងអស់ ត្រូវផ្ដល់សេវាធ្វើតេស្តរហ័សដល់ប្រជាពលរដ្ឋ ក្នុងតម្លៃទាបសមស្រប ដោយប្រើប្រាស់ឧបករណ៍តេស្តរហ័សដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

៦. ឱសថស្ថាននិងឱសថស្ថានរង ត្រូវលក់ឧបករណ៍តេស្តរហ័សក្នុងតម្លៃសមស្រប ដើម្បីឱ្យប្រជាពលរដ្ឋមានលទ្ធភាពទិញយកមកធ្វើតេស្ត ដោយមានការត្រួតពិនិត្យឱ្យបានហ្មត់ចត់ដោយក្រុមការងារសិក្សា និងស្រាវជ្រាវរកឱសថនិងបរិក្ខារសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩។

៧. មូលដ្ឋានសុខាភិបាលសាធារណៈទាំងអស់ ត្រូវប្រើប្រាស់ឧបករណ៍តេស្តរហ័សផ្ដល់ជូនដោយក្រសួងសុខាភិបាល។ សមត្ថកិច្ចពាក់ព័ន្ធត្រូវគ្រប់គ្រងនិងត្រួតពិនិត្យឱ្យបានច្បាស់លាស់ ដើម្បីទប់ស្កាត់កុំឱ្យឧបករណ៍របស់រដ្ឋមាននៅលើទីផ្សារ។



ទីស្ដីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័នរដ្ឋ រដ្ឋបាលរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តផ្សព្វផ្សាយ និងតាមដានការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈប្រតិបត្តិ**
**នៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

ម៉ម ប៊ុនហេង

**កន្លែងទទួល៖**

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- លេខាធិការដ្ឋានរបស់គណៈប្រចាំការនៃ គ.ប.ក.
- លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃ គ.អ.ក.
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ